## សលាកប័ត្រព័ត៌មាន ៖ ការយល់ព្រមដោយពេញចិត្ត ដោយបានប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ

**ទិដ្ឋភាពរួម ៖** ទស្សនទានជុំវិញការយល់ព្រមដោយពេញចិត្ត និងប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ ("ការយល់ព្រមជាមុន") គឺជាបទដ្ឋានមួយដែលត្រូវបានទទួលស្គាល់ជាលក្ខណៈអន្តរជាតិដែលអនុវត្តលើការប្រឹក្សាយោបល់ជាមួយជនជាតិដើមភាគតិច។ ការព្រមព្រៀងជាមុនត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថាជាការអនុវត្តដ៏ប្រសើរបំផុតក្នុងការស្វែងរកមតិយោបល់របស់ជនជាតិដើមភាគតិចទាក់ទិនទៅនឹងសកម្មភាពទាំងឡាយដែលប៉ះពាល់ពួកគេ និងដីធ្លីរបស់ពួកគេ ព្រមទាំងធានាថាសិទ្ធិទាំងអស់របស់ពួកគេត្រូវបានគោរព។ រាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") បានបង្ហាញពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការការពារសិទ្ធិរបស់ជនជាតិដើមភាគតិចជាច្រើនតាមរយៈ ការបង្កើតគោលនយោបាយជាក់លាក់ក្នុងគោលបំណងការពារសិទ្ធិជនជាតិដើមភាគតិចទាំងនោះ។ ការទទួលស្គាល់សារសំខាននិងការអនុវត្តទស្សនទាននៃការយល់ព្រមជាមុននៅក្នុងប្រទេសកម្ពុជានិងការតម្រូវឱ្យធុរកិច្ចទាំងឡាយមានការប្រឹក្សាយោបល់ប្រកបដោយអត្ថន័យជាមួយសហគមន៍ជនជាតិដើមភាគតិច ដែលអាចនឹងទទួលរងផលប៉ះពាល់អវិជ្ជមានដោយសារទម្រង់ណាមួយនៃធុរកិច្ច ឬគម្រោងអភិវឌ្ឍន៍គឺជាជំហានបន្ទាប់ដ៏ត្រឹមត្រូវសម្រាប់រដ្ឋាភិបាល។ ស្រដៀងគ្នានេះដែរ ធុរកិច្ចដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជាគួរតែគោរពទស្សនទាននៃការព្រមព្រៀងជាមុន ថាជាការអនុវត្តដ៏ប្រសើរបំផុត ក្នុងការជួយលើកស្ទួយនិរន្តរភាពនៃប្រតិបត្តិការរបស់ខ្លួន ព្រមទាំងបំពេញតាមការទទួលខុសត្រូវក្នុងការគោរពសិទ្ធិមនុស្ស។

### សេចក្តីផ្តើម

សលាកប័ត្រព័ត៌មាននេះផ្តល់នូវទិដ្ឋភាពទូទៅនៃទស្សនទានជុំវិញការយល់ព្រមជាមុន ផ្តល់ជាការវិភាគពីបញ្ញាច្បាប់សំខាន់ៗទាក់ទងនឹងការយល់ព្រមជាមុន និងពិចារណាអំពីការអនុវត្តគោលការណ៍នៃការយល់ព្រមជាមុននៅក្នុងប្រទេសកម្ពុជាគិតត្រឹមបច្ចុប្បន្ននេះ ។ សលាកប័ត្រព័ត៌មាននេះតាក់តែងឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក")ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ពន្ធ ដែលធ្វើការងារដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា")។

### សាវតារ

កម្ពុជាគឺជាប្រទេសដែលមានកំណើនទីផ្សារកំពុងរីកលូតលាស់ ដែលគួរឱ្យចាប់អារម្មណ៍ក្នុងប៉ុន្មានទសវត្សរ៍ថ្មីៗនេះ ដោយសារតែកំណើននៃការវិនិយោគបរទេស និងធនធានធម្មជាតិដ៏សម្បូរបែបរបស់ប្រទេស។ មួយភាគធំនៃដីធ្លីត្រូវបានផ្តល់ទៅឱ្យវិនិយោគិនថ្នាក់អន្តរជាតិ ថ្នាក់តំបន់ និងក្នុងស្រុក សម្រាប់គម្រោងអភិវឌ្ឍន៍កសិ-ឧស្សាហកម្ម ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ។ ទោះជាយ៉ាងណា ការអភិវឌ្ឍសេដ្ឋកិច្ចនេះក៏បណ្តាលឱ្យមានការរំលោភបំពានសិទ្ធិដីធ្លីនិងមាន

ការសឹករេចរឹលដល់បរិស្ថាន ជាពិសេសដោយសារបេបសម្បទានដីសេដ្ឋកិច្ច[1] រួមមានទាំងផលប៉ះពាល់ដល់ដីដែលកាន់កាប់ដោយជនជាតិដើមភាគតិច។[2]

## តើការយល់ព្រមដោយពេញចិត្ត និងដោយបានប្រាប់ជាមុន និងទទួលបានព័ត៌មានពេញលេញជាអ្វី?

ការយល់ព្រមជាមុន គឺជាបទដ្ឋានមួយដែលត្រូវបានការពារដោយអនុសញ្ញានៃអង្គការពលកម្មអន្តរជាតិលេខ ១៦៩[3] និងសេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច ("សេចក្តីប្រកាសស្តីពីជនជាតិដើមភាគតិច") ហើយការយល់ព្រមជាមុននេះអនុវត្តលើករណីណាដែលការផ្លាស់ប្តូរទីលំនៅថ្មីរបស់ជនជាតិដើមភាគតិចស្ថិតក្នុងហានិភ័យ។[4] ទស្សនទាននៃការយល់ព្រមជាមុនអាចត្រូវបានពន្យល់ដូចខាងក្រោមនេះ ៖

- **ពេញចិត្ត** ៖ ពុំមានការបង្ខិតបង្ខំ ការបំភិតបំភ័យ ឬ ការបំភ័ន្ត។
- **ដោយបានប្រាប់ឱ្យដឹងជាមុន** ៖ ត្រូវតែមានការស្វែងរកការយល់ព្រមឱ្យបានគ្រប់គ្រាន់មុនការអនុញ្ញាត ឬ ការចាប់ផ្តើមសកម្មភាព។ ត្រូវតែមានពេលវេលាគ្រប់គ្រាន់សម្រាប់ដំណើរការពិគ្រោះយោបល់ជាមួយជនជាតិដើមភាគតិច។
- **ទទួលបានព័ត៌ពេញលេញ** ៖ ជនជាតិដើមភាគតិចគួរទទួលបានព័ត៌មានពេញលេញទាក់ទងនឹងគម្រោងអភិវឌ្ឍន៍នានា រួមទាំងការវាយតម្លៃបឋមអំពីផលប៉ះពាល់ដល់សេដ្ឋកិច្ច សង្គម និងបរិស្ថានរបស់គម្រោងនោះ។ ជាពិសេស អ្នកដែលពាក់ព័ន្ធទាំងឡាយគួរទទួលបានព័ត៌មាននេះ និងព័ត៌មានទាំងនេះជាព័ត៌មានត្រឹមត្រូវ។
- **ការយល់ព្រម** ៖ ជាដំណើរការក្នុងពិគ្រោះយោបល់និងការចូលរួមដែលតំណាងឱ្យសសរស្តម្ភស្នូល។[5]

នៅក្នុងការអនុវត្តជាក់ស្តែង ចំណុចនេះតម្រូវឱ្យអ្នកអភិវឌ្ឍទាំងឡាយទទួលស្គាល់ និងគោរពវប្បធម៌របស់ជនជាតិដើមភាគតិច ក៏ដូចជាទំនាក់ទំនងពិសេសដោយឡែករវាងជនជាតិដើមភាគតិច និងដីធ្លីរបស់ពួកគេ។ តម្លៃនៃជំនឿដែលពួកគេគោរពជាទីសក្ការៈ និងដែលអាចទទួលរងនូវផលប៉ះពាល់នៃគម្រោងដល់ដីធ្លីរបស់ពួកគេកាន់តែធ្ងន់ធ្ងរនោះ ក៏ត្រូវតែយកមកពិចារណាផងដែរ។ ឧទាហរណ៍ ការគោរពការយល់ព្រមជាមុនអាចតម្រូវឱ្យមានការបង្កើតដំណើរការប្រឹក្សាយោបល់ដោយមានការចូលរួមពេញលេញ និងតម្លាភាពដែលគោរពរចនាសម្ព័ន្ធផ្នែកអភិបាលកិច្ច និងភាពជាអ្នកដឹកនាំរបស់សហគមន៍ជនជាតិដើមភាគតិច តម្រូវឱ្យមានការចូលរួមប្រឹក្សាយោបល់មុនចាប់ផ្តើមការអភិវឌ្ឍ ដូច្នេះហើយមតិយោបល់ទាំងឡាយរបស់សហគមន៍អាចត្រូវបានយកទៅពិចារណា និងតម្រូវឱ្យមានការផ្តល់ព័ត៌មានអំពីគម្រោងអភិវឌ្ឍទាំងនោះ ដែលសហគមន៍អាចស្វែងរកព័ត៌មានទាំងនេះបានដឹងជាភាសាដើមរបស់ពួកគេ។ ការប្រឹក្សាយោបល់គួរតែធ្វើឡើងក្នុងទម្រង់ជាការផ្លាស់ប្តូរមតិយោបល់គ្នា ដែលអនុញ្ញាតឱ្យសម្រេចបាននូវការយល់ព្រមគ្នាទៅវិញទៅមក។

## ស្ថានភាពផ្នែកច្បាប់នៃទស្សនទានជុំវិញការយល់ព្រមជាមុននៅប្រទេសកម្ពុជា

---

[1] សូមមើលរបាយការណ៍របស់ ម.ស.ម.ក "កម្ពុជា ៖ ដីមានជម្លោះ" (ខែធ្នូ ឆ្នាំ២០១៣) http://bit.ly/1KtPNVy

[2] សូមមើលកំណត់ត្រាសង្ខេបរបស់ ម.ស.ម.ក "ការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា" (ខែកុម្ភៈ ឆ្នាំ២០១៦) http://bit.ly/1o0z3wi

[3] មាត្រា១៦ សូមមើលអត្ថបទទាំងស្រុងនៃអនុសញ្ញានេះតាមរយៈ http://bit.ly/1HP8BLq

[4] មាត្រា១០ សូមមើលអត្ថបទទាំងស្រុងនៃសេចក្តីប្រកាសនេះតាមរយៈ http://bit.ly/1bKIrMs

[5] របាយការណ៍របស់សិក្ខាសាលាអន្តរជាតិស្តីអំពីវិធីសាស្ត្រទាក់ទងនឹងការយល់ព្រមដោយសេរី និងដោយបានប្រាប់ឱ្យដឹងជាមុន និងជនជាតិដើមភាគតិច (ទីក្រុង ញូវយ៉ក ថ្ងៃទី១៧-១៩ ខែមករា ឆ្នាំ២០០៥) ឯកសាររបស់ អ.ស.ប E/C.១៩/២០០៥/៣ កថាខណ្ឌទី ៤៦ http://bit.ly/2hi24oR

ប្រទេសមួយត្រូវចងភ្ជាប់កាតព្វកិច្ចជាមួយនឹងសន្ធិសញ្ញាអន្តរជាតិទាំងឡាយណា ដែលខ្លួនបានផ្តល់សច្ចាប័ន និងច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលត្រូវបានកំណត់ថាជការអនុវត្តទូទៅ និងដោយស៊ីសង្វាក់គ្នារបស់បណ្តារដ្ឋនានាដែលបានអនុវត្តបន្តៗគ្នាដោយយល់ឃើញថាជាកាតព្វកិច្ចច្បាប់។[6] ថ្វីបើប្រទេសកម្ពុជាមិនទាន់បានផ្តល់សច្ចាប័នដល់អនុសញ្ញាអង្គការពលកម្មអន្តរជាតិ លេខ១៦៩ ដែលផ្សារភ្ជាប់កាតព្វកិច្ចនៃការយល់ព្រមជាមុននៅឡើយនោះ ប៉ុន្តែប្រទេសកម្ពុជាបានបោះឆ្នោតគាំទ្រសេចក្តីប្រកាសស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច។[7] ដោយសារតែសេចក្តីប្រកាសស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិចមានរៀបរាប់ទស្សនទាននៃការយល់ព្រមជាមុនដល់ទៅ ៦ ដង (ដែលមាននៅក្នុងមាត្រា ១០ មាត្រា ១១ មាត្រា ១៩ មាត្រា ២៨ មាត្រា ២៩ និងមាត្រា ៣២) ហើយដែលត្រូវបានអនុម័តដោយរដ្ឋជាង១៤៨ នៃរដ្ឋចំនួន១៥៩ នោះ សេចក្តីសម្រេចនេះបង្ហាញពីឆន្ទៈនយោបាយដ៏រឹងមាំមួយរបស់សហគមន៍អន្តរជាតិចំពោះទស្សនទានការយល់ព្រមជាមុន។[8] ការអនុវត្តរបស់រដ្ឋ និងការឯកភាពទទួលយកកាន់តែច្រើនឡើងជុំវិញការយល់ព្រមជាមុនត្រូវបានបង្ហាញឱ្យឃើញជាបន្តបន្ទាប់តាមរយៈកំណើននៃសេចក្តីថ្លែងការណ៍ជាសាធារណៈ របាយការណ៍ សេចក្តីណែនាំ និងគោលនយោបាយជាច្រើនទៀតរបស់ពហុស្ថាប័នរបស់អង្គការសហប្រជាជាតិ និងស្ថាប័នអន្តរជាតិផ្សេងទៀតដែលទទួលស្គាល់គោលការណ៍នៃការយល់ព្រមជាមុនថាជាឧបករណ៍ចាំបាច់ដើម្បីការពារ និងផ្តល់ប្រសិទ្ធភាពដល់សិទ្ធិជាមូលដ្ឋានសំខាន់ៗជាច្រើនទៀត។[9] ឧទាហរណ៍មួយគឺ គោលការណ៍ណែនាំស្ម័គ្រចិត្តរបស់អង្គការស្បៀង និងកសិកម្មរបស់សហប្រជាជាតិស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ដីធ្លី [10] ដែលជាបទដ្ឋានអន្តរជាតិដ៏សំខាន់មួយបានផ្តល់ជាអនុសាសន៍ថា នៅទីណាដែលគម្រោងអភិវឌ្ឍន៍អាចប៉ះពាល់ដល់ធនធានដែលសហគមន៍ជនជាតិដើមមានសិទ្ធិកាន់កាប់ ការអភិវឌ្ឍគម្រោងនោះ"គួរតែធ្វើឡើងដោយផ្អែកលើការពិគ្រោះយោបល់ប្រកបដោយប្រសិទ្ធភាពនិងប្រកបដោយអត្ថន័យ ជាមួយជនជាតិដើមភាគតិច តាមរយៈស្ថាប័នតំណាងរបស់ខ្លួនដើម្បីទទួលបានការយល់ព្រមដោយពេញចិត្ត និងដោយបានប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញរបស់ពួកគេ។"[11]

ស្រដៀងគ្នានេះដែរស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សបានធ្វើការចង្អុលបង្ហាញជាញឹកញាប់ចំពោះភាពចំបាច់សម្រាប់រដ្ឋនានាក្នុងការពិគ្រោះយោបល់ជាមួយជនជាតិដើមភាគតិច បើទោះបីជាស្ថាប័នទាំងនោះមានការប្រុងប្រយ័ត្នក្នុងការសំដៅលើគោលការណ៍នៃការយល់ព្រមជាមុន ថាជាបទដ្ឋានមួយដែលត្រូវចងជាកាតព្វកិច្ចក៏ដោយ។ គណៈកម្មាធិការ

---

[6] ករណីធ្នេរសមុទ្រភាគខាងជើង (សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ទល់នឹងដាណឺម៉ាក សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ទល់នឹងហូឡង់) [ឆ្នាំ1969] តុលាការយុត្តិធម៌អន្តរជាតិ [74] – [77] http://bit.ly/2w0ocaK

[7] ប្រព័ន្ធព័ត៌មានគន្លងនិទ្ទេសរបស់ អ.ស.ប, កំណត់ត្រាស្តីពីការបោះឆ្នោតគាំទ្រលើសេចក្តីប្រកាសស្តីពីសិទ្ធិជនជាតិដើមភាគតិច http://bit.ly/2v1W4UM

[8] សាកលវិទ្យាល័យបច្ចេកទេសស៊ីដនី "សេចក្តីសង្ខេបអំពីសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច" (ឆ្នាំ២០០៧) http://bit.ly/2ueBdLK ។ សម្រាប់ប្រភពយោងផ្សេងទៀតស្តីអំពីការយល់ព្រមជាមុន សូមមើល "គោលការណ៍ណែនាំស្ម័គ្រចិត្តរបស់អង្គការស្បៀង និងកសិកម្មរបស់សហប្រជាជាតិ ស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើសិទ្ធិកាន់កាប់ដីធ្លី ធនធានជលផល និងធនធានព្រៃឈើ" (ឆ្នាំ២០១២) http://bit.ly/1lZY3gX, "សេចក្តីណែនាំរបស់ អូអ៊ីស៊ីឌី និងអង្គការស្បៀង និងកសិកម្ម សម្រាប់ខ្សែសង្វាក់ផ្គត់ផ្គង់ផលិតផលកសិកម្មប្រកបដោយការទទួលខុសត្រូវ" (ឆ្នាំ២០១៦) http://bit.ly/2vnL5aW

[9] កម្មវិធីរបស់ អ.ស.ប "សេចក្តីណែនាំស្តីពីការយល់ព្រមដោយសេរី និងដោយបានប្រាប់ឱ្យដឹងជាមុន" (ឆ្នាំ២០១៣) ១៤ http://bit.ly/2tYaKH0

[10] អង្គការស្បៀង និងកសិកម្មរបស់សហប្រជាជាតិ គោលការណ៍ណែនាំដោយស្ម័គ្រចិត្តស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើសិទ្ធិកាន់កាប់ដីធ្លី ធនធានជលផល និងធនធានព្រៃឈើ នៅក្នុងបរិបទសុវត្ថិភាពស្បៀងថ្នាក់ជាតិ (ឆ្នាំ២០១២) http://bit.ly/1lZY3gX

[11] ប្រភពដូចខាងលើ នៅក្នុងកថាខ័ណ្ឌទី ៩(៩)

របស់អង្គការសហប្រជាជាតិទទួលបន្ទុកក្នុងការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ("គណៈកម្មាធិការលុបបំបាត់ការរើសអើង") បានបញ្ជាក់ថារដ្ឋភាគីទាំងឡាយត្រូវ "ខិតខំដើម្បីទទួលបាន" ការយល់ព្រម[12] "ស្វែងរក" ការយល់ព្រម[13] ឬ"ប្រឹក្សាយោបល់"[14] ជាមួយជនជាតិដើមភាគតិច។ នៅក្នុងការសេចក្ដីអត្ថាធិប្បាយជាទូទៅលេខ ២១ របស់គណៈកម្មាធិការអង្គការសហប្រជាតិទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ("គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌") បានសម្រេចថារដ្ឋនានាត្រូវប្រតិបត្តិតាមគោលការណ៍នៃការយល់ព្រមជាមុន "នៅពេលការអភិរក្សធនធានវប្បធម៌របស់ [ជនជាតិដើមភាគតិច] [...] ប្រឈមនឹងហានិភ័យ"។[15]

ដូចបានលើកឡើងខាងលើ ប្រទេសកម្ពុជាគួរគោរពការប្ដេជ្ញាជាអន្តរជាតិចំពោះទស្សនទាននៃការយល់ព្រមជាមុន នៅគ្រាដែលកម្ពុជាបានបោះឆ្នោតគាំទ្រសេចក្ដីប្រកាសស្ដីពីសិទ្ធិរបស់ជនជាតិដើមភាគតិច និងត្រូវអនុវត្តស្របទៅតាមការប្ដេជ្ញានេះ។ ជាងនេះទៀត ការអនុវត្តតាមទស្សនទាននៃការយល់ព្រមជាមុននាំមកនូវផលប្រយោជន៍ជាក់ស្ដែងមួយចំនួនដូចជា ការអនុវត្តតាមនេះមិនត្រឹមតែធានាដល់ការគោរពសិទ្ធិមនុស្សរបស់ជនជាតិដើមភាគតិចប៉ុណ្ណោះទេ ប៉ុន្តែតាមរយៈការធានាឱ្យមានការទទួលយកគម្រោងអភិវឌ្ឍន៍ខ្នាតធំនានាដោយសហគមន៍មូលដ្ឋាននោះ នឹងកាន់តែជួយលើកកម្ពស់និរន្តរភាពរបស់គម្រោង ក៏ដូចជាលទ្ធភាពជោគជ័យផ្នែកពាណិជ្ជកម្ម និងហិរញ្ញវត្ថុរបស់គម្រោងអភិវឌ្ឍន៍ទាំងនោះផងដែរ។[16]

## ការអនុវត្តទស្សនទាននៃការយល់ព្រមជាមុនក្នុងប្រទេសកម្ពុជា

នៅឆ្នាំ២០០៩ រដ្ឋាភិបាលបានបង្កើតគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍសហគមន៍ជនជាតិដើមភាគតិចដែលមានគោលបំណងលើកកម្ពស់ជីវភាពនិងគុណភាពរស់នៅរបស់ជនជាតិដើមភាគតិច។ រដ្ឋាភិបាលក៏បានបង្កើតគោលនយោបាយចុះបញ្ជីដីធ្លីថ្នាក់ជាតិ និងអនុក្រឹត្យលេខ៨៣ ត្រូវបានអនុម័តដែលផ្ដោតជាពិសេសទៅលើនីតិវិធីក្នុងការចុះបញ្ជីដីធ្លីដោយជនជាតិដើមភាគតិច។ រហូតមកទល់ពេលនេះ សហគមន៍ជនជាតិដើមភាគតិចចំនួន ១៨ បានទទួលប័ណ្ណកម្មសិទ្ធិសមូហភាពដែលជាការបង្ហាញពីការទទួលស្គាល់សិទ្ធិរបស់ពួកគេលើដីធ្លីជាផ្លូវការដោយរដ្ឋាភិបាល។ ស្រដៀងគ្នានេះដែរ មានសហគមន៍ចំនួន ១២៤ ត្រូវបានទទួលស្គាល់ជាផ្លូវការដោយក្រសួងអភិវឌ្ឍន៍ជនបទ ហើយមានសហគមន៍ចំនួន ១១១ មានលក្ខណៈសម្បត្តិជានីតិបុគ្គលតាមផ្លូវច្បាប់ដែលទទួលស្គាល់ដោយក្រសួងមហាផ្ទៃ។[17] ការទទួលស្គាល់ទាំងនេះគឺជាជំហានវិជ្ជមានមួយ ប៉ុន្តែទោះជាយ៉ាងណា ជាញឹកញាប់ គម្លាតនៃការអនុវត្តច្បាប់ធ្វើឱ្យជនជាតិដើមភាគតិចនៅប្រឈមនឹងភាពងាយរងគ្រោះពីផលប៉ះពាល់អវិជ្ជមានដែលកើតចេញពីសកម្មភាពទាំងឡាយរបស់ធុរកិច្ច។ ខណៈក្នុងស្ថានភាពខ្លះ ច្បាប់ជាតិតម្រូវឱ្យមានការវាយតម្លៃផលប៉ះពាល់ និងការពិគ្រោះយោបល់មុនពេលគម្រោងអភិវឌ្ឍន៍អាចចាប់ផ្ដើមធ្វើ ជារឿយៗសហគមន៍មិនត្រូវបានសូម្បីតែប្រាប់ដំណឹងមុនពេលដែលគម្រោងអភិវឌ្ឍន៍ចាប់ផ្ដើមបង្កផលប៉ះពាល់ដល់ដីធ្លី និងជីវភាពរស់នៅរបស់ពួកគេនោះទេ។ ជាញឹកញាប់នៃគម្រោងអភិវឌ្ឍន៍ ហាក់ដូចជាពុំមានការស្វែងរកមតិ

[12] ប្រទេសហ្គាតេម៉ាឡា CERD/C/GTM/CO/11 [ឆ្នាំ២០០៦] [១៩]។

[13] ប្រទេសហ្គាយ៉ាណា CERD/C/GUY/CO/14 [ឆ្នាំ២០០៦] [១៤]។

[14] ប្រទេសកូឡុំប៊ែរ CERD/C/COL/CO/14 [ឆ្នាំ២០០៩] [20]។

[15] ស៊ី.អ៊ី.អែស.ស៊ី.អ័រ ការផ្ដល់យោបល់ជាទូទៅ លេខ២១ [២០០៩] [៥៥ (អ៊ី)]។

[16] កម្មវិធីរបស់អ.ស.ប "សេចក្ដីណែនាំស្ដីពីការយល់ព្រមដោយសេរី និងដោយបានប្រាប់ឱ្យដឹងជាមុន" (ឆ្នាំ២០១៣) កថាខណ្ឌទ១៦។

[17] នាយករដ្ឋមន្ត្រី ហ៊ុន សែន "លិខិតចំហក្នុងឱកាសអបអរសាទរទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោកលើកទី២៣" (ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧) http://bit.ly/2vyxNsj។

យោបល់ប្រកបដោយអត្ថន័យពេញលេញពីសហគមន៍អំពីផលប៉ះពាល់ ដែលអាចកើតមានលើពួកគេដោយសារគម្រោងអភិវឌ្ឍន៍ឡើយ។ ដូចជាពុំមានការពិគ្រោះយោបល់ដើម្បីពិភាក្សាអំពីលទ្ធភាពនៃការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានណាមួយទៅលើសិទ្ធិរបស់សហគមន៍នោះដែរ។ ការទទួលស្គាល់ និងការអនុវត្តទស្សនទាននៃការយល់ព្រមជាមុនប្រកបដោយប្រសិទ្ធភាពនឹងអាចជួយធានាថា សិទ្ធិទាំងឡាយរបស់ជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជាត្រូវបានគោរពក្នុងការអនុវត្តជាក់ស្តែង។ ករណីសិក្សាពីរខាងក្រោមនេះបង្ហាញពីផលលំបាកដែលសហគមន៍ជនជាតិដើមភាគតិចកម្ពុជាប្រឈម និងផលវិបាកដ៏ធំធេងដែលកើតចេញពីកង្វះការគោរពចំពោះគោលការណ៍នៃការយល់ព្រមជាមុន។

## ករណីសិក្សាទី ១ ៖ ជនជាតិដើមភាគតិចព្នងបានរងផលប៉ះពាល់ពីចម្ការកៅស៊ូនៅឃុំប៊ូស្រា ខេត្តមណ្ឌលគិរី

ចាប់តាំងពីឆ្នាំ២០០៨ មក ជនជាតិដើមភាគតិចទាំងនេះបានទទួលរងគ្រោះបាត់បង់ដីធ្លី ដោយសារសម្បទានដីសេដ្ឋកិច្ចសម្រាប់ដាំកៅស៊ូ នៅក្នុងឃុំប៊ូស្រា ខេត្តមណ្ឌលគិរី។ សម្បទានដីសេដ្ឋកិច្ចទាំងពីរកន្លែងនេះ បច្ចុប្បន្នគ្រប់គ្រងដោយក្រុមហ៊ុន សុកហ្វីន ខេស៊ីឌី ដែលជាបុត្រសម្ព័ន្ធរបស់បណ្តុំក្រុមហ៊ុន សុកហ្វីន ដែលជាសហគ្រាសកសិ-ឧស្សាហកម្មអន្តរជាតិដែលមានមូលដ្ឋាននៅប្រទេសឡុចសំប៊ួ។ សហគមន៍មូលដ្ឋានមិនត្រូវបានពិគ្រោះយោបល់ត្រឹមត្រូវឡើយមុនពេលដែលសម្បទានដីសេដ្ឋកិច្ចត្រូវបានផ្តល់ឱ្យទៅក្រុមហ៊ុន ហើយការឈូសឆាយដីបានចាប់ផ្តើម មុនពេលបញ្ចប់ការចរចាអំពីសំណង។ សម្បទានដីនេះបានធ្វើឱ្យប៉ះពាល់ជាង៨៥០គ្រួសារ ដែលភាគច្រើនគឺសហគមន៍ជនជាតិដើមភាគតិចព្នង[18] ដែលបានរស់នៅឃុំប៊ូស្រា ជាច្រើនជំនាន់ទៅហើយ។ ជនជាតិដើមភាគតិចព្នងប្រើប្រាស់ដីរបស់ពួកគេសម្រាប់ដាំដុះធ្វើកសិកម្ម ប្រារព្ធជំនឿចំពោះព្រៃឈើទុកជាទីសក្ការៈ និងសម្រាប់កប់សព។[19] ការទន្ទ្រានលើដីធ្លីពួកគេបង្កឱ្យមានគ្រោះថ្នាក់ដល់វប្បធម៌ សហគមន៍ និងរបៀបរស់នៅពិសេសដោយឡែករបស់អ្នកទាំងនោះ។[20] ជនជាតិដើមភាគតិចព្នងបានដាក់ពាក្យបណ្តឹងជាច្រើនទៅអាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរថ្នាក់ជាតិ ហើយក៏បានដាក់នៅឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សផងដែរ។ ទោះបីជាយ៉ាងនេះក៏ដោយ សមាជិកសហគមន៍ទាំងនេះនៅមិនទាន់ទទួលបានសំណងពេញលេញនៅឡើយទេ។

## ករណីសិក្សាទី២ ៖ ជនជាតិដើមភាគតិច នៅក្បាលរមាស ខេត្តស្ទឹងត្រែង ត្រូវបានផ្លាស់ប្តូរទីលំនៅថ្មីដោយសារទំនប់វារីអគ្គិសនីសេសាន

នៅឆ្នាំ២០១២ រដ្ឋាភិបាលបានយល់ព្រមឱ្យមានគម្រោងសាងសង់ទំនប់វារីអគ្គិសនីនៅតាមដងទន្លេមេគង្គ។ នៅពេលគម្រោងនេះបញ្ចប់ គម្រោងនេះនឹងក្លាយទៅជាទំនប់វារីអគ្គិសនីដ៏ធំបំផុតនៅកម្ពុជា ហើយក៏មានផលប៉ះពាល់ធ្ងន់ធ្ងរលើបរិស្ថាន រួមទាំងមច្ឆាផងដែរ។ [21] ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់នោះមិនត្រូវបានអាជ្ញាធរជូនដំណឹងជាមុនអំពីសេចក្តីសម្រេចនេះឡើយ ហើយពួកគេក៏មិនធ្លាប់ទទួលព័ត៌មានស្តីពីផលប៉ះពាល់ដល់សិទ្ធិនានាក្នុងនាមជាជនជាតិដើម

[18] សហព័ន្ធអន្តរជាតិដើម្បីសិទ្ធិមនុស្ស, 'ដីកម្ពុជាត្រូវបានឈូសសម្អាតសម្រាប់ការដាំកៅស៊ូ' (ឆ្នាំ២០១១) ៥, http://bit.ly/1rTdm2h.
[19] ម.ស.ម.ក, "ប៊ូស្រា ខេត្តមណ្ឌលគិរី" អាចរកបានតាមរយៈ http://bit.ly/2mnER57.
[20] សូមអានបន្ថែមអំពីផលវិបាកនៃសម្បទានដីសេដ្ឋកិច្ចនៅឃុំប៊ូស្រា តាមរយៈកាសែត ឌេលី ម៉ែល 'ភាពខ្មះខ្មែងរបស់កម្ពុជាសម្រាប់ការជំរុញការដាំកៅស៊ូបង្ខំឱ្យជនជាតិដើមភាគតិចចេញពីដីរបស់ខ្លួន' (ឆ្នាំ២០១៦) តាមរយៈ http://dailym.ai/2sAFNGo.
[21] ការស្ទង់មតិដោយទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា 'គោលនយោបាយសំណង និងតម្លៃអចលនទ្រព្យ –គម្រោង អភិវឌ្ឍន៍ទំនប់វារីអគ្គិសនីសេសានក្រោម២" (ឆ្នាំ២០១៥) តាមរយៈ http://bit.ly/2wfzMhm.

ភាគតិចដែលទទួលរងគ្រោះនោះដែរ។[22] សព្វថ្ងៃនេះ ទំនប់វារីអគ្គិសនីនេះស្ទើរតែជិតបញ្ចប់ការសាងសង់ទាំងស្រុងហើយ ប៉ុន្តែស្ថានភាពរបស់ជនជាតិដើមភាគតិចស្ទើរតែ ១៨០ គ្រួសារ ដែលបន្តរស់នៅក្នុងភូមិចំនួនពីរដែលនឹងទទួលរងការជន់លេចក្នុងពេលឆាប់ៗ នៅមិនទាន់មានដំណោះស្រាយនៅឡើយទេ។ ចំនួនភាគច្រើននៃអ្នកទាំងនេះគឺជាជនជាតិដើមភាគតិចព្នង ឬមកពីក្រុមភាគតិចឡាវ។ ដោយមានការភ័យខ្លាចចំពោះការបាត់បង់ដីធ្លី និងទំនៀមទម្លាប់របស់ពួកគេ ដូច្នេះហើយពួកគេបានបដិសេធទទួលយកការផ្តល់ជាសំណងជាកញ្ចប់។ ដូចគ្នាដែរ ពួកគេមិនព្រមផ្លាស់ប្តូរទៅតាំងទីលំនៅថ្មីដែលនៅឆ្ងាយពីដងទន្លេ និងស្ថិតក្នុងតំបន់ដែលសម្បូរដោយដីគ្មានជីជាតិសម្រាប់បង្កបង្កើនផលកសិកម្ម។ ពួកគេក៏កំពុងធ្វើការតវ៉ាអំពីការរុះរើស្ពានចោលដែលពួកគេប្រើប្រាស់ជាមធ្យោបាយឆ្លងកាត់យ៉ាងងាយស្រួលចូលទៅកាន់ទីប្រជុំជនជិតៗគ្នាដែលមានសេវាកម្មព្យាបាលជម្ងឺ សាលារៀន និងផ្សារ។ ពលរដ្ឋមិនទទួលបានផ្លូវជំនួសផ្សេងដើម្បីធ្វើការកាត់នោះទេ។[23] ទោះបីជាមានការជំទាស់ទាំងនេះក្តី ទ្វារទំនប់ទឹកទាំងនោះត្រូវបានបើកដំណើរការកាលពីចុងខែកក្កដានេះសម្រាប់ការធ្វើការតេស្តសាកល្បង ដែលនាំឱ្យមានទឹកជំនន់នៅតាមភូមិនានាដែលសហគមន៍មូលដ្ឋានកំពុងរស់នៅ។

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

រដ្ឋាភិបាលគួរធានាថា គោលការណ៍នៃការយល់ព្រមជាមុនត្រូវបានអនុវត្ត និងគោរពថាជាបទដ្ឋានមួយសម្រាប់ការចូលរួមប្រឹក្សាយោបល់ជាមួយនឹងជនជាតិដើមភាគតិចទាំងអស់នៅកម្ពុជា ទាំងនៅពេលដែលមានផ្តួចផ្តើមគម្រោងអភិវឌ្ឍន៍ដំបូងរបស់រដ្ឋាភិបាល និងទាំងពេលដែលធុរកិច្ចកំពុងប្រតិបត្តិការនៅកម្ពុជា។

**<u>អនុសាសន៍សម្រាប់រដ្ឋាភិបាល ៖</u>**

- *ផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការពលកម្មអន្តរជាតិ លេខ ១៦៩ អនុសញ្ញាស្តីពីជនជាតិដើមភាគតិច និងកុលសម្ព័ន្ធ។*
- *ធានាថាគម្រោងអភិវឌ្ឍន៍ទាំងអស់ ជាពិសេស ការផ្តល់សម្បទានសេដ្ឋកិច្ច តំបន់សេដ្ឋកិច្ចពិសេស និងគម្រោងហេដ្ឋារចនាសម្ព័ន្ធនានាត្រូវបានធ្វើទៅដោយមានការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយនឹងសហគមន៍រងផលប៉ះពាល់ រួមទាំងជនជាតិដើមភាគតិច។*
- *ចាត់វិធានការអនុវត្តឱ្យមានប្រសិទ្ធភាពប្រឆាំងនឹងធុរកិច្ច ឬអាជ្ញាធរថ្នាក់ក្រោមជាតិ ដែលខកខានមិនបានបំពេញកាតព្វកិច្ចតាមផ្លូវច្បាប់របស់ខ្លួន ក្នុងការវាយតម្លៃពីផលប៉ះពាល់ និងចូលរួមក្នុងការពិគ្រោះយោបល់ រួមទាំងលុបចោលការផ្តល់សម្បទានដីសេដ្ឋកិច្ច ឬ តំបន់សេដ្ឋកិច្ចពិសេស ក្នុងករណីពាក់ព័ន្ធ។*
- *ចែងឱ្យបានច្បាស់លាស់អំពីទស្សនទាននៃការយល់ព្រមជាមុននៅក្នុងច្បាប់ជាតិ ហើយធ្វើវិសោធនកម្មច្បាប់ពាក់ព័ន្ធដើម្បីតម្រូវឱ្យមានការគោរពគោលការណ៍នៃការយល់ព្រមជាមុន នៅពេលណាគម្រោងអភិវឌ្ឍន៍អាចបង្កផលប៉ះពាល់ដល់ជនជាតិដើមភាគតិច។*
- *ចេញសេចក្តីណែនាំដើម្បីផ្តល់ភាពច្បាស់លាស់សម្រាប់ធុរកិច្ច និងអាជ្ញាធរថ្នាក់ក្រោមជាតិ អំពីរបៀបដែលអ្នកទាំងនេះអាចបំពេញតាមគោលការណ៍នៃការយល់ព្រមជាមុនក្នុងការអនុវត្តជាក់ស្តែង។*

---

[22] 'ការពង្រឹងនូវការទទួលខុសត្រូវ និងការរួមបញ្ចូលនៅក្នុងគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ច–ករណីសិក្សាទំនប់វារីអគ្គិសនីសេសានក្រោម២' តាមរយៈ http://bit.ly/2vnnmrt.

[23] 'គ្រួសារជាច្រើននៅតំបន់សេសានក្រោម២ ត្រូវប្រឈមការជម្លៀសចេញដោយបង្ខំ និងការជន់លេចនាពេលអនាគត" (ឆ្នាំ២០១៧) ទន្លេអន្តរជាតិតាមរយៈ http://bit.ly/2hiy8ZM.

**<u>អនុសាសន៍សម្រាប់ធុរកិច្ចដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា៖</u>**

- *មុននឹងចាប់ផ្តើមគម្រោងណាមួយដែលអាចប៉ះពាល់ទៅដល់ជនជាតិដើមភាគតិច ធុរកិច្ចត្រូវមានការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ ដោយត្រូវធ្វើស្របតាមគោលការណ៍នៃការយល់ព្រមជាមុន។*
- *ដាក់បញ្ចូលការប្តេជ្ញាចិត្តជាក់លាក់អំពីគោលការណ៍នៃការយល់ព្រមជាមុននៅក្នុងគោលនយោបាយរបស់ក្រុមហ៊ុន និងចេញផ្សាយរបាយការណ៍អំពីការអនុវត្តនេះជាប្រចាំ។*
- *នៅពេលណាដែលគោលការណ៍នៃការយល់ព្រមជាមុនមិនទាន់ត្រូវបានគោរពយ៉ាងពេញលេញក្នុងការដោះស្រាយលើកមុនៗជាមួយជនជាតិដើមភាគតិចដែលទទួលរងផលប៉ះពាល់ពីប្រតិបត្តិការរបស់ធុរកិច្ចទនោះ ត្រូវធានាថារាល់ផលប៉ះពាល់អវិជ្ជមានដល់សិទ្ធិមនុស្សត្រូវបានកាត់បន្ថយប្រកបដោយប្រសិទ្ធភាព និងផ្តល់សំណងឱ្យបានសមរម្យ។*

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងលោក វណ្ណ សុផាត អ្នកសម្របសម្រួលគម្រោងធុរកិច្ចនិងសិទ្ធិមនុស្ស តាមរយៈលេខទូរសព្ទ ០១២ ៩៤១ ២០៦ ឬ អ៊ីម៉ែល vann.sophath@cchrcambodia.org.*

---------